**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងពាណិជ្ជកម្ម　　ធនាគារជាតិ នៃ កម្ពុជា

ថ្ងៃសុក្រ ៣កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ការអនុវត្តច្បាប់ស្តីពី កិច្ចការពារអ្នកប្រើប្រាស់ និងប្រកាសស្តីពី ខសន្យាមិនសុចរិត ក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ

ច្បាប់ស្តីពី កិច្ចការពារអ្នកប្រើប្រាស់ ត្រូវបានប្រកាសឱ្យប្រើ តាមរយៈព្រះរាជក្រមលេខ នស/រកម/១១១៩/០១៦ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩។ ជាមួយគ្នានេះ គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ «គ.ជ.ក.ប.» ក៏ត្រូវបានបង្កើតឡើងតាមរយៈអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ ដែលមានរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មជាប្រធាន និងមានតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងនោះក៏មានការចូលរួមពីតំណាងធនាគារជាតិនៃកម្ពុជា។ គ.ជ.ក.ប. មានតួនាទីរៀបចំនិងផ្សព្វផ្សាយគោលនយោបាយ និងផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនឹងកិច្ចការពារអ្នកប្រើប្រាស់ ព្រមទាំងដឹកនាំនិងត្រួតពិនិត្យលើការអនុវត្តច្បាប់ស្តីពី កិច្ចការពារអ្នកប្រើប្រាស់ ឱ្យមានប្រសិទ្ធភាពខ្ពស់។

កន្លងមកនេះ យើងសង្កេតឃើញថា ការប្រើប្រាស់ទម្រង់ស្តង់ដានៃកិច្ចសន្យារបស់បុគ្គលធ្វើធុរកិច្ចមួយចំនួន មិនអាចផ្តល់លទ្ធភាពឱ្យអ្នកប្រើប្រាស់ស្នើសុំកែប្រែខចែងឬលក្ខខណ្ឌណាមួយនៃកិច្ចសន្យា ដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់ពួកគាត់ឡើយ។ ទម្រង់ស្តង់ដានៃកិច្ចសន្យាមួយចំនួន បានបង្កប់នូវខ្លឹមសារនិងខសន្យាមិនសុចរិត ដើម្បីកេងយកចំណេញហួសហេតុពីអ្នកប្រើប្រាស់។ ខសន្យាមិនសុចរិតទាំងនោះមានជាអាទិ៍៖ ខចែងអំពីការលើកលែង ឬកម្រិតការទទួលខុសត្រូវរបស់បុគ្គលធ្វើធុរកិច្ចលើការធានាលើទំនិញនិង/ឬសេវារបស់ខ្លួន ខចែងដែលផ្តល់សិទ្ធិឱ្យបុគ្គលធ្វើធុរកិច្ចអាចកែប្រែឬផ្លាស់ប្តូរចំណុចសំខាន់ណាមួយលើប្រភេទ បរិមាណ តម្លៃ និងគុណភាពនៃទំនិញនិង/ឬសេវា ឬកែប្រែខសន្យាសំខាន់ៗនៃទម្រង់ស្តង់ដានៃកិច្ចសន្យាផ្សេងទៀត ដោយមិនតម្រូវឱ្យមានការជូនដំណឹងនិងការយល់ព្រមជាមុនពី

អ្នកប្រើប្រាស់ និងខសន្យាដែលផ្តល់សិទ្ធិឱ្យបុគ្គលធ្វើធុរកិច្ចអាចបកស្រាយដោយឯកតោភាគី ឬរំលាយកិច្ចសន្យាតាមឆន្ទានុសិទ្ធិរបស់បុគ្គលធ្វើធុរកិច្ច។

ដើម្បីគាំទ្រដល់ការអនុវត្តច្បាប់ស្តីពី កិច្ចការពារអ្នកប្រើប្រាស់ ក្រសួងពាណិជ្ជកម្មបានរៀបចំប្រកាសលេខ០០៦៧ ព.ណ.អ.កបប.ប្រក ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០២២ ស្តីពីខសន្យាមិនសុចរិត សំដៅការពារផលប្រយោជន៍អ្នកប្រើប្រាស់ ទប់ស្កាត់ការបង្កើតទម្រង់ស្តង់ដានៃកិច្ចសន្យាដែលមិនសុចរិត និងមានលក្ខណៈកេងចំណេញពីអ្នកប្រើប្រាស់។ កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ ក្រសួងពាណិជ្ជកម្ម បានសហការជាមួយធនាគារជាតិនៃកម្ពុជា រៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពី «ច្បាប់ស្តីពី កិច្ចការពារអ្នកប្រើប្រាស់ និងប្រកាសស្តីពី ខសន្យាមិនសុចរិត» ជូនអ្នកចូលរួមចំនួន ១៧០ នាក់ មកពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្រសួងពាណិជ្ជកម្ម និងធនាគារជាតិនៃកម្ពុជា សូមក្រើនរំលឹកដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្តឱ្យបានត្រឹមត្រូវស្របតាមខ្លឹមសារនៃច្បាប់ស្តីពី កិច្ចការពារអ្នកប្រើប្រាស់ និងប្រកាសស្តីពី ខសន្យាមិនសុចរិត ដើម្បីការពារសិទ្ធិអ្នកប្រើប្រាស់ និងជំរុញឱ្យការប្រកួតប្រជែងប្រកបដោយតម្លាភាព។

ទន្ទឹមនេះ ក្រសួងពាណិជ្ជកម្ម និងធនាគារជាតិនៃកម្ពុជា សូមអំពាវនាវដល់សាធារណជន ជាពិសេសអ្នកប្រើប្រាស់អាចរាយការណ៍ពាក់ព័ន្ធនឹងអំពើកេងយកចំណេញហួសហេតុដោយកើតចេញពីការបង្កើតនូវទម្រង់ស្តង់ដានៃកិច្ចសន្យាដែលមិនសុចរិតពីបុគ្គលធ្វើធុរកិច្ចមក អគ្គនាយកដ្ឋាន ការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំតាមរយៈអាសយដ្ឋាន៖ ផ្លូវ១៨ ភូមិក្តីតាកុយ សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ និងតាមរយៈលេខទូរស័ព្ទ៖ (១). ០២៣ ២៣១ ៨៥៦ និង (២). ០៩២ ៨៣០ ៨៥៦ ឬអាចទំនាក់ទំនងមក ធនាគារជាតិនៃកម្ពុជា តាមរយៈអាសយដ្ឋាន៖ លេខ៦៩-៧០ មហាវិថីហាណូយ ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ និងតាមរយៈលេខទូរស័ព្ទ៖ (១). ០៨៥ ៦០០ ០០២ (២). ០៨៥ ៦០០ ០០៣ (៣). ០៩៨ ២២០ ០០១ (៤). ០៩៨ ២២០ ០០២ និង (៥). ០៩៧ ២៧៨ ៣០៣០។